ក៏ប៉ុន្តែ ប្រសិនបើគ្រួសាររបស់លោកអ្នក<u>មិនបានទទួល</u> ប្រាក់ Food Stamp,
ប្រាក់កម្មវិធីផ្តល់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ(TANF) ប្រាក់កម្មវិធីចែកចាយម្ហូបអាហារ
នៅកន្លែងជនជាតិ INDIAN (FDPIR) ទេនោះ សូមបំពេញសំណុំពាក្យសុំផលកម្រៃម្ហូបអាហារនេះ(Meal Benefit Form) ហើយកុំភ្លេច:

- ផ្តល់ឈ្មោះរបស់សមាជិកក្រុមគ្រួសារទាំងអស់ ព្រមទាំងប្រាក់ចំណូលរបស់ពួកគេ
  ដោយបង្ហាញនូវប្រភពនៃប្រាក់ចំណូលនោះ ព្រមទាំង
- ឱ្យមនុស្សធំពេញវ័យ ចុះហត្ថលេខា បំពេញថ្ងៃខែ ព្រមទាំងបំពេញលេខ SOCIAL SECURITY
  របស់ខ្លួន នៅលើពាក្យសុំផលកម្រៃម្ហូបអាហារផងដែរ ឬមួយក៏ សរសេរថា “none”
  ប្រសិនបើមនុស្សធំពេញវ័យនោះ គ្មានលេខ SOCIAL SECURITY ទេនោះ ។

<u>សម្រាប់គ្រួសារទាំងអស់</u>:

ក្រសួងកសិកម្មសហរដ្ឋអាមេរិក ចាត់ទុកបុគ្គលមួយក្រុម(មិនមែនអ្នករស់នៅ ក្នុងផ្ទះសំណាក់១ ឬវិជ្ជាស្ថាន១នោះទេ) ដែលរស់នៅក្នុងអង្គភាពសេដ្ឋកិច្ចមួយ (បានសេចក្តីថា ជួយចេញសោហ៊ុយចាយវាយ) ថាជាគ្រួសារតែ១ ។ ដូច្នេះ ប្រាក់ចំណូលដែលរាយការ នៅក្នុងសំណុំពាក្យសុំប្រាក់ផលកម្រៃម្ហូបអាហារនោះ(Meal Benefit Form) ចាំបាច់ត្រូវតែ បញ្ចូលទាំងប្រាក់ចំណូលមិនទាន់ ដកហូតពន្ធដារ របស់សមាជិកទាំងអស់ នៅក្នុងគ្រួសារលោកអ្នក ដោយបញ្ចេញប្រភពនិមួយៗ ។

ប្រាក់ចំណូល ដែលលោកអ្នករាយការ ចាំបាច់ត្រូវតែជាប្រាក់ចំណូល ទាំងអស់មុនការដកហូតយកពន្ធដារចេញ តាមប្រភពនិមួយៗ សម្រាប់សមាជិកម្នាក់ៗ ក្នុងគ្រួសារ ដែលបានទទួលកាលពីខែមុន ។

ប្រសិនបើប្រាក់ចំណូលពីខែមុន មិនឆ្លុះបញ្ចាំងនូវកាលៈទេសៈ របស់លោកអ្នក ឱ្យបានពិតប្រាកដទេនោះ លោកអ្នកអាចដាក់ចំនួន ដែលលោកអ្នក ទស្សន៍ទាយ ថាជាប្រាក់ចំណូលប្រចាំខែ របស់លោកអ្នកនោះ ។ ប្រសិនបើគ្មានការផ្លាស់ប្តូរអ្វី ធំដុំកើតឡើងទេនោះ លោកអ្នកអាចយកប្រាក់ចំណូលកាលពីខែមុន មកធ្វើជាគោលមួយ សម្រាប់ធ្វើការទស្សន៍ទាយនេះ ។ ប្រសិនបើប្រាក់ចំណូលក្នុងក្រុមគ្រួសារ របស់លោកអ្នក ស្មើ